# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអធិដ្ឋានពេញមួយយប់លើកទី៥៦នៅបឹងទំពុន
# ថ្ងៃទី០៥ មករា ២០១៧

អត្ថបទទី១៖ ១យហា ៣,១១-២១
ដំណឹងល្អ៖ យហា ១,៤៣-៥១

បងប្អូនជាទីស្រឡាញ់!

យប់នេះជាយប់ទី៥៦ ដែលយើងបានអធិដ្ឋានសម្រាប់ការត្រាស់ហៅ ជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់។ ថ្ងៃនេះយើងបានស្ដាប់ថា **"សូមអញ្ជើញមកអ្នកនឹងបានឃើញ"** នេះជាពាក្យដែលព្រះយេស៊ូចង់ប្រាប់ដល់យើង ឲ្យយើងឃើញព្រះយេស៊ូតែម្ដង។ អត្ថបទទីមួយ **"ដំណឹងដែលបងប្អូនបានទទួលតាំងពីដើមដំបូងរៀងមក នោះគឺយើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក"** យើងចូលនៅក្នុងគ្រឹះនៃជំនឿរបស់យើង។ យើងមិនមែនស្រឡាញ់គ្នាទៅវិញទៅមកតាមរបៀបលោកីយ៍ ស្រឡាញ់គ្នាទៅវិញទៅមកតាមរបៀបសន្តប៉ូលថា **"យើងស្គាល់សេចក្ដីស្រឡាញ់ស្រាប់ហើយ គឺព្រះយេស៊ូបានបូជាព្រះជន្មរបស់ព្រះអង្គសម្រាប់យើង ហេតុនេះយើងត្រូវបូជាជីវិតសម្រាប់បងប្អូនដែរ"** យើងចូលយ៉ាងជ្រៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូសម្រាប់យើង គឺព្រះយេស៊ូបានបូជាព្រះជន្មរបស់ព្រះអង្គសម្រាប់យើង ហេតុនេះយើងត្រូវការបូជាជីវិតសម្រាប់បងប្អូនដែរ។ យើងធ្វើតាមព្រះយេស៊ូ ដើម្បីឃើញអ្វីដែលកើតឡើងគឺជីវិតរបស់ព្រះយេស៊ូ ដែលណែនាំឲ្យយើងទទួលសេចក្ដីស្រឡាញ់ពីព្រះអង្គ ជាពិសេសណែនាំឲ្យយើងចែសេចក្ដីស្រឡាញ់នេះជាមួយបងប្អូនឯទៀតៗ ដូចសន្តប៉ូលបាននិយាយ **"ប្រសិនបើនរណាម្នាក់មានសម្បត្តិលោកីយ៍ ហើយឃើញបងប្អូនរបស់ខ្លួនខ្វះខាត តែបែជាមិនអាណិតអាសូរអ្នកនោះទេ ធ្វើដូចម្ដេចម្ដងចនឹងឲ្យសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ស្ថិតនៅក្នុងខ្លួនអ្នកនោះកើត"**។ ស្រឡាញ់ដូចព្រះយេស៊ូជារបៀបមួយថ្មី ដោយសារយើងធ្វើតាមព្រះយេស៊ូពិតមែននិងណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី។

ដូច្នេះចាប់ពីពេលនេះតទៅយើងត្រូវការគិត នៅពេលខ្ញុំមានអាយុ៨៥ឆ្នាំតើជីវិតខ្ញុំបានធ្វើអ្វីខ្លះ? ត់ជីវិតខ្ញុំបានធ្វើតាមព្រះបន្ទូលរបស់ព្រះយេស៊ូឬទេ? តើជីវិតខ្ញុំសុខចិត្តលះបង់ចោលអ្វីដែលណែនាំឲ្យមានសេចក្ដីសុខសាន្តលោកីយ៍ឬទេ? ជីវិតរបស់ខ្ញុំជាអ្វី?។ សព្វថ្ងៃសង្គមរបស់យើងប្រែប្រួលយ៉ាងខ្លាំង ប៉ុន្តែសម្រាប់យើងជាគ្រីស្ដបរិស័ទយើងត្រូវការបង្កើតប្រពៃណីថ្មីដើម្បីបម្រើបងប្អូនឯទៀត ដើម្បីបើកភ្នែករបស់យើងថែមទៀត។ សម្ដេចប៉ាបបានសរសេរលិខិតជូនលោកអភិបាលទូទាំងពិភពលោកទាំងមូលថា **"សូមលោកអភិបាលបើកភ្នែក សូមលោកអភិបាលជួយមើលនៅក្នុងពិភពលោករបស់យើងមានកូនក្មេងច្រើនណាស់ដែលឥតមានសេចក្ដីសុខសាន្ត ដែលកំពុងស្លាប់ដោយសារខ្វះម្ហូបអាហារ ដែលខ្វះការទទួលការអប់រំ ប្រសិនបើយើងមិនផ្លាស់ប្ដូររបៀបនេះ នៅឆ្នាំ**

**២០៦០ មានកូនក្មេងទូទាំងពិភពលោកទាំងមូល១៧០លាន់ ដែលខ្វះការអប់រំ"។ ពីមួយឆ្នាំទៅមួយឆ្នាំចន្លោះ១០ឆ្នាំខាងមុខនេះ ប្រសិនបើយើងមិនណែនាំឲ្យសេវាកម្មសុខភាពរីកចម្រើន កូនក្មេងអាយុក្រោម៥ឆ្នាំ ត្រូវស្លាប់ចំនួន ៦០លាននាក់"។** លោកអភិបលអើយសូមភ្ញាក់ស្មារតី ដើម្បីជួយព្រះសហគមន៍ ជួយឲ្យគ្រីស្តបរិស័ទចេះបើកភ្នែក ដើម្បីឲ្យយើងរៀបចំអនាគតរបស់កូនក្មេងនៅក្នុងពិភពលោកទាំងមូល។ ខ្ញុំបានធ្វើរបាយការណ៍និងរូបភាពសកម្មភាព ដែលយើងបានធ្វើជាមួយកូនក្មេងជាមួយអ្នកក្រីក្រ ជាអ្នកចាស់ជរា ក្នុងថ្ងៃបុណ្យព្រះយេស៊ូប្រសូត ជូនទៅអគ្គរាជ្យទូតដើម្បីដឹងថាពិតមែនយើងកំពុងយកចិត្តទុកដាក់ជាមួយកូនក្មេង ចាស់ជរា អ្នកក្រីក្រ ដើម្បីរៀបចំអនាគត។ នេះជាឱកាសមួយដើម្បីស្តាប់ព្រះបន្ទូល **"សេចក្តីស្រឡាញ់កើតឡើង លុះត្រាតែយើងសុខចិត្តលះបង់ចោលនិងបូជាជីវិតរបស់យើងពិតមែន"** គឺដើរតាមរបៀបព្រះយេស៊ូ មិនដើរតាមលោកីយ៍ដែលយើងឃើញសព្វថ្ងៃទេ។

អត្ថបទរបស់សន្តយ៉ូហាន **"កូនចៅអើយយើងមិនត្រូវស្រឡាញ់ត្រឹមតែបបូរមាត់ឬពាក្យសំដីប៉ុណ្ណោះទេ យើងត្រូវស្រឡាញ់តាមអំពើដែលយើងប្រព្រឹត្តនិងតាមសេចក្តីពិតវិញ"** នេះជាព្រះបន្ទូលមួយដែលយើងត្រូវការឆ្លាក់នៅក្នុងបេះដូងរបស់យើង នៅក្នុងខួរក្បាលរបស់យើង នៅក្នុងដៃរបស់យើង កុំឲ្យយើងយើងស្រឡាញ់តែបបូរមាត់។ យើងធ្វើដូចម្តេច ដើម្បីឲ្យឆ្នាំមេត្តាករុណា និងឆ្នាំមហាករុណាទិគុណ ដែលយើងបានធ្វើ៣ឆ្នាំកន្លងមកបន្តទៀត ដើម្បីឲ្យជីវិតរបស់យើងជាគ្រីស្តបរិស័ទកាតូលិកកម្ពុជា ទៅជាជីវិតមួយដ៏អស្ចារ្យដើម្បីណែនាំឲ្យសេចក្តីស្រឡាញ់យាងចូលនៅគ្រប់ទីកន្លែង ជាពិសេសកន្លែងដែលមានកូនក្មេង មានយុវជន មានចាស់ជរា មានអ្នកក្រីក្រ មានជនពិការ មានអ្នកអស់សង្ឃឹម ដើម្បីនៅពេលយើងមានអាយុ៨៥ឆ្នាំយើងទទួលបានជីវិតសប្បាយពីព្រះជាម្ចាស់ ដោយសារយើងបានអនុវត្តតាមព្រះបន្ទូលរបស់ព្រះយេស៊ូ។ ពីពេលនេះដែលយើងត្រូវការស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលអញ្ជើញយើងឲ្យយើងដើរតាមព្រះអង្គ ដើម្បីរួមរស់នៅក្នុងសេចក្តីស្រឡាញ់យ៉ាងពិសេសដែលព្រះអង្គបានប្រទានឲ្យយើង។ **"ខ្ញុំសូមប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នករាល់គ្នានឹងឃើញផ្ទៃមេឃបើកចំហ ហើយមានពួកទេវទូតរបស់ព្រះជាម្ចាស់ចុះឡើងពីលើបុត្រមនុស្សវិញ"** នេះជាសេចក្តីសង្ឃឹមរបស់យើង ពេលយើងមានអាយុ៨៥ឆ្នាំ យើងឃើញពួកទេវទូតនេះមកទទួលស្វាគមន៍យើង ដោយសារអស់មួយជីវិតរបស់យើង យើងបានខិតខំអនុវត្តព្រះបន្ទូរបស់ព្រះយេស៊ូជាក់ស្តែង គឺយើងត្រូវតែស្រឡាញ់គ្នាទៅវិញទៅមកមិនមែនត្រឹមតែបបូរមាត់ ប៉ុន្តែដោយយើងប្រព្រឹត្ត និងតាមសេចក្តីពិតមែន។ យប់នេះយើងអធិដ្ឋាន ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះយេស៊ូ **សូមអញ្ជើញមកអ្នកនឹងបានឃើញ** ចូលយ៉ាងជ្រៅនៅក្នុងជីវិតរបស់យើង ឲ្យយើងសម្រេចចិត្តថ្ងៃនេះពិតមែនព្រះយេស៊ូចាត់ខ្ញុំ ដើម្បីឲ្យខ្ញុំជួយសង្គមខ្ញុំទៅជាសង្គមថ្មីប្រកបដោយសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះអង្គពិតមែន។ អាម៉ែន។